រាជបណ្ឌិត្យសភាកម្ពុជា

# ទំនាក់ទំនងនយោបាយកម្ពុជា-ជប៉ុន
# (២០០៨-២០១៨)

## Cambodia-Japan Political Relations (2008-2018)

ហុង សុវណ្ណសុនិតា

សារណាបរិញ្ញាបត្រជាន់ខ្ពស់

ជំនាញ : វិទ្យាសាស្ត្រនយោបាយ

២០២៣

រាជបណ្ឌិត្យសភាកម្ពុជា

# ទំនាក់ទំនងនយោបាយកម្ពុជា-ជប៉ុន
# (២០០៨-២០១៨)

## Cambodia-Japan Political Relations (2008-2018)

ហុង សុវណ្ណសុនិតា

គ្រូណែនាំ : បណ្ឌិត គិន ភា

ព្រះរាជាណាចក្រកម្ពុជា
បណ្ណាល័យ
លេខ 0 0 1 2 6 9 7 -
រាជបណ្ឌិត្យសភាកម្ពុជា

សារណាបរិញ្ញាបត្រជាន់ខ្ពស់

ជំនាញ : វិទ្យាសាស្ត្រនយោបាយ

ឆ្នាំ ២០២៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
រាជបណ្ឌិត្យសភាកម្ពុជា

Royal Academy of Cambodia
Académie Royale du Cambodge

**លេខ : ០៣៤ /២១ ស.ស.រ.**

# សេចក្ដីសម្រេច

## ស្ដីពី

## ការអនុញ្ញាតឱ្យការពារសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

- បានឃើញព្រះរាជក្រឹត្យ នស/រកត/១២១៩/១៩៦២ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងអនុក្រឹត្យ លេខ១២៤ អនក.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២០ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃរាជបណ្ឌិត្យសភាកម្ពុជា
- បានឃើញសេចក្ដីសម្រេចលេខ ១១ ស.ស.រ. ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៥ ស្ដីពីការបណ្ដុះបណ្ដាលថ្នាក់ក្រោយបរិញ្ញាបត្របង់ថ្លៃសិក្សាស្រាវជ្រាវនៅរាជបណ្ឌិត្យសភាកម្ពុជា
- យោងគោលការណ៍ស្ដីពីការបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅរាជបណ្ឌិត្យសភាកម្ពុជា
- យោងចំណារឯកភាពរបស់គ្រូណែនាំចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២១

## សម្រេច

**ប្រការ ១** : អនុញ្ញាតឱ្យកញ្ញា **ហុង សុវណ្ណនិតា** និស្សិត **ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី៦ វគ្គ១** ជំនាញ **វិទ្យាសាស្ត្រនយោបាយ**ការពារសារណាបញ្ចប់នៅថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ២០២១

**ប្រការ ២** : គណៈកម្មការវាយតម្លៃសារណា មជ្ឈមណ្ឌលបណ្ដុះបណ្ដាលនិងស្រាវជ្រាវ នៃរាជបណ្ឌិត្យសភាកម្ពុជា និងសាមីខ្លួនត្រូវអនុវត្តសេចក្ដីសម្រេចនេះឱ្យមានប្រសិទ្ធភាពប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ ព្រហស្បតិ៍ ១១រោច ខែ ស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ សីហា ឆ្នាំ២០២១

**ប្រធាន**

បណ្ឌិតសភាចារ្យ **សុខ ទូច**

អាសយដ្ឋាន ៖ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ - ប្រអប់សំបុត្រលេខ៥៣១ ភ្នំពេញ កម្ពុជា
Tel/Fax: (855) 23 890 180, Website: www.rac.gov.kh, E-mail: info@rac.gov.kh, P.O.Box 531 Phnom Penh, Cambodia

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
រាជបណ្ឌិត្យសភាកម្ពុជា

Royal Academy of Cambodia
Académie Royale du Cambodge

លេខ : ០៣៧ / ២១ ឧ.ន.ន.

# លិខិតឧទ្ទេសនាម
## គណៈកម្មការវាយតម្លៃការការពារសារណាបញ្ចប់
## ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

| ល.រ. | គោត្តនាម និង នាម | ជំនាញ | តួនាទី |
|---|---|---|---|
| ១ | បណ្ឌិត **ភា ម៉ាធុល** | វិទ្យាសាស្ត្រនយោបាយ | ប្រធាន |
| ២ | បណ្ឌិត **គិន ភា** | វិទ្យាសាស្ត្រនយោបាយ | គ្រូណែនាំ |
| ៣ | បណ្ឌិត **ចាន់ ម៉ុនី** | ប្រវត្តិវិទ្យា | សមាជិក |
| ៤ | បណ្ឌិត **ខែក វីរៈ** | វិទ្យាសាស្ត្រនយោបាយ | សមាជិក |
| ៥ | បណ្ឌិត **ស៊ឹន សំ** | វិទ្យាសាស្ត្រនយោបាយ | សមាជិក |

- និស្សិត : **ហុង សុវណ្ណនិតា** - ភេទ : ស្រី
- ជំនាញ : **វិទ្យាសាស្ត្រនយោបាយ** - **ជំនាន់ទី៦ វគ្គ១**
- ប្រធានបទ : **ទំនាក់ទំនងនយោបាយកម្ពុជា-ជប៉ុន(២០០៨-២០១៨)**
- គ្រូណែនាំ : បណ្ឌិត **គិន ភា**
- កាលបរិច្ឆេទការពារ : ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២១ - ម៉ោង : ៩:០០ នាទី

ថ្ងៃព្រហស្បតិ៍ ៣រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១
ប្រធាន

បណ្ឌិតសភាចារ្យ **សុខ ទូច**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
រាជបណ្ឌិត្យសភាកម្ពុជា

Royal Academy of Cambodia
Académie Royale du Cambodge

**ប្រធានបទ៖ «ទំនាក់ទំនងនយោបាយកម្ពុជា-ជប៉ុន ឆ្នាំ២០០៨-២០១៨»**

គណៈកម្មការវាយតម្លៃសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញ វិទ្យាសាស្ត្រនយោបាយ
បញ្ជាក់ថា៖ បេក្ខជនបរិញ្ញាបត្រជាន់ខ្ពស់ **ហុង សុវណ្ណសុនិតា**
ពិតជាបានការពារសារណាបរិញ្ញាបត្រជាន់ខ្ពស់បញ្ចប់ដោយជោគជ័យ នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២១ ពិតប្រាកដមែន។

| | |
|---|---|
| បណ្ឌិត **ភា ម៉ាធុល** | ប្រធានគណៈកម្មការ |
| បណ្ឌិត **ចាន់ ប៊ុន្នី** | គ្រូវាយតម្លៃទី១ |
| បណ្ឌិត **ស៊ីន សំ** | គ្រូវាយតម្លៃទី២ |
| បណ្ឌិត **ខេក វីរៈ** | គ្រូវាយតម្លៃទី៣ |
| បណ្ឌិត **គិន ភា** | គ្រូណែនាំ |

**អគ្គលេខាធិការរង**
**ទទួលបន្ទុកមជ្ឈមណ្ឌលបណ្តុះបណ្តាលនិងស្រាវជ្រាវ**

**សុក្រ សំណាង**

**ប្រធានរាជបណ្ឌិត្យសភាកម្ពុជា**

បណ្ឌិតសភាចារ្យ **សុខ ទូច**

អាសយដ្ឋាន ៖ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ - ប្រអប់សំបុត្រលេខ៥៣១ ភ្នំពេញ កម្ពុជា
Tel/Fax: (855) 23 890 180, Website: www.rac.gov.kh, E-mail: info@rac.gov.kh, P.O.Box 531 Phnom Penh, Cambodia

# មាតិកា

ទំព័រ


ឧទ្ទិសស្នាដៃ ....... i

សេចក្តីថ្លែងអំណរគុណ ....... ii

អំណះអំណាង ....... iii

បញ្ជីអក្សរកាត់ ....... iv

មូលន័យសង្ខេបជាភាសាខ្មែរ ....... vii

Abstract ....... ix

សេចក្តីសង្ខេបជាភាសាខ្មែរ ....... x

Summary in English Language ....... xiii

សេចក្តីផ្តើម ....... 1

១. លំនាំបញ្ហានៃការសិក្សាស្រាវជ្រាវ ....... 1

២. គោលបំណងនៃកិច្ចការសិក្សាស្រាវជ្រាវ ....... 2

៣. ចំណោទបញ្ហានៃការសិក្សាស្រាវជ្រាវ ....... 3

៤. ដែនកំណត់និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ ....... 3

៥. វិធីសាស្រ្តសិក្សាស្រាវជ្រាវ ....... 3

៦. ការរំលឹកទ្រឹស្តី ....... 5

៧. ក្របខ័ណ្ឌគំនិតនៃការសិក្សាស្រាវជ្រាវ ....... 15

៨. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ ....... 18

៩. រចនាសម្ព័ន្ធនិក្ខេបបទ ....... 19

ជំពូកទី១ ....... 22

ក្របខ័ណ្ឌទ្រឹស្តីនៃទំនាក់ទំនងការទូត ....... 22

១.១ ដំណើរការបង្កើតគោលនយោបាយការបរទេស ......22
១.១.១ ការវាយតម្លៃលើបរិបទនយោបាយក្នុងស្រុកនិងអន្តរជាតិ ......22
១.១.២ ការកំណត់ជម្រើសគោលនយោបាយ ......23
១.១.៣ សកម្មភាពធ្វើសេចក្ដីសម្រេចចិត្តជាផ្លូវការ......24
១.១.៤ ការអនុវត្តជម្រើសគោលនយោបាយដែលបានជ្រើសរើសរួច ......24
១.២ គោលដៅនៃគោលនយោបាយការបរទេស ......25
១.៣ កត្តាកំណត់នៃគោលនយោបាយការបរទេស ......26
១.៣.១ កត្តាកំណត់ខាងក្រៅ (External Determinants) ......26
១.៣.២ កត្តាកំណត់ខាងក្នុង (Internal Determinants) ......28
១.៤ ការវិភាគគោលនយោបាយការបរទេស ......31
១.៤.១ ម៉ូដែលសំខាន់២ប្រភេទសម្រាប់វិភាគគោលនយោបាយការបរទេស ......32
១.៤.២ ទ្រឹស្ដីសេរីនិយម (Liberalism) សម្រាប់វិភាគគោលនយោបាយការបរទេស ......35
១.៥ ការដំឡើងកម្រិតទំនាក់ទំនងអន្តរជ្ឈ ......37
១.៥.១ ការដំឡើងកម្រិតទំនាក់ទំនងរដ្ឋទៅជាភាពជាដៃគូយុទ្ធសាស្ត្រ......38
១.៥.២ ការដំឡើងកម្រិតទំនាក់ទំនងអន្តរដ្ឋទៅជាភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ ......40
១.៦ តថភាពពិតនៃពិភពលោក......41
១.៧ ការនិទស្សន៍កម្រិតទំនាក់ទំនងអន្តរជ្ឈ ......42
ជំពូកទី២ ......45
ទំនាក់ទំនងកម្ពុជា-ជប៉ុន ......45
២.១ គោលនយោបាយការបរទេសកម្ពុជា......45
២.១.១ គោលការណ៍ទូទៅនៃគោលនយោបាយការបរទេសកម្ពុជា ......48
២.១.២ គោលនយោបាយការបរទេសកម្ពុជាចំពោះជប៉ុន......50
២.២ គោលនយោបាយការបរទេសជប៉ុន......51

២.២.១ គោលការណ៍ទូទៅនៃគោលនយោបាយការបរទេសជប៉ុន ........ 52
២.២.២ គោលនយោបាយការបរទេសជប៉ុនចំពោះកម្ពុជា ........ 62
២.៣ ទិដ្ឋភាពរួមនៃទំនាក់ទំនងកម្ពុជា-ជប៉ុន ឆ្នាំ២០០៨-២០១៨ ........ 65
២.៣.១ ការគាំទ្រគ្នាទៅវិញទៅមកលើឆាកអន្តរជាតិ ........ 65
២.៣.២ ការផ្លាស់ប្តូរទស្សនកិច្ចរវាងប្រទេសទាំងពីរ ឆ្នាំ២០០៨-២០១៨ ........ 67
២.៣.៣ កម្ពុជានៅចន្លោះជប៉ុននិងចិន ........ 81
ជំពូកទី៣ ........ 92
ទស្សនវិស័យនៃទំនាក់ទំនងកម្ពុជា-ជប៉ុន ........ 92
៣.១ ទិដ្ឋភាពនយោបាយ ........ 92
៣.២ ទិដ្ឋភាពសេដ្ឋកិច្ច ........ 99
៣.៣ បញ្ហាប្រឈមនៃទំនាក់ទំនងកម្ពុជា-ជប៉ុន ........ 102
៣.៤ អនាគតនៃទំនាក់ទំនងកម្ពុជា-ជប៉ុន ........ 103
សេចក្តីសន្និដ្ឋាន ........ 105
អនុសាសន៍ ........ 110
បញ្ជីគន្ថនិទ្ទេស ........ 113

# មូលន័យសង្ខេបជាភាសាខ្មែរ

ក្នុងកិច្ចការសិក្សាស្រាវជ្រាវនេះ គឺមានចំណងជើងថា «ទំនាក់ទំនងនយោបាយកម្ពុជា-ជប៉ុន ឆ្នាំ២០០៨ ដល់ឆ្នាំ២០១៨» ដោយមានដែននៃការសិក្សាស្រាវជ្រាវពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៨ និងមានវិសាលភាពនៃការសិក្សាស្រាវជ្រាវលើវិស័យនយោបាយតែប៉ុណ្ណោះ។ កិច្ចការសិក្សាស្រាវជ្រាវពីប្រធានបទនេះ មានគោលបំណងសំខាន់៣រួមមាន (១) ពិនិត្យទៅលើគោលនយោបាយការបរទេសប្រទេសកម្ពុជានិងប្រទេសជប៉ុនពីឆ្នាំ២០០៨-២០១៨ (២) កំណត់កត្តាដែលនាំឱ្យទំនាក់ទំនងកម្ពុជានិងជប៉ុនក្លាយជាទំនាក់ទំនងភាពជាដៃគូយុទ្ធសាស្ត្រនៅឆ្នាំ២០១៣ (៣) និទស្សន៍ពីកម្រិតទំនាក់ទំនងកម្ពុជា-ជប៉ុននាពេលអនាគតថាតើទំនាក់ទំនងទ្វេភាគីនេះអាចក្លាយជាទំនាក់ទំនងភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយដែរឬទេ។

ក្នុងកិច្ចការសិក្សាស្រាវជ្រាវនេះគឺប្រើប្រាស់ទាំងទិន្នន័យទីមួយ និងទិន្នន័យទីពីរ ដោយប្រើនូវវិធីសាស្ត្របែបគុណភាព ធ្វើការពិព័ណ៌នា វិភាគ ពន្យល់ ក៏ដូចជាធ្វើការសម្ភាសន៍លើអ្នកពាក់ព័ន្ធមួយចំនួនបែបការសម្ភាសន៍មិនតាមលំដាប់លំដោយ (Unstructured interview) ដោយក្នុងនោះ មានការសម្ភាសន៍បែបបម្រុះបែប In-depth interviews, Focus group interviews និង Narratives។ ដោយឡែក ក៏មានធ្វើការធ្វើរកម្រងសំណួរតាមរយៈ Google Form ទៅកាន់មន្ត្រីនិងអ្នកពាក់ព័ន្ធមួយចំនួនផងដែរ។

ទន្ទឹមនឹងនេះផងដែរ នៅក្នុងកិច្ចការសិក្សាស្រាវជ្រាវនេះ គឺចែកចេញជា៣ ជំពូក។ នៅក្នុងជំពូកទី១ មានចំណងជើងថា «ក្របខ័ណ្ឌទ្រឹស្តីនៃទំនាក់ទំនងការទូត»។ នៅក្នុងជំពូកនេះ គឺសិក្សាអំពីដំណើរការនៃការធ្វើគោលនយោបាយការបរទេស ដោយក្នុងនោះរួមមាន ការវាយតម្លៃលើបរិបទក្នុងស្រុកនិងអន្តរជាតិ ការកំណត់ជម្រើសគោលនយោបាយ សកម្មភាពធ្វើសេចក្តីសម្រេចចិត្តជាផ្លូវការ និងការអនុវត្តជម្រើសគោលនយោបាយដែលបានជ្រើសរើសរួច។ ការសិក្សានេះក៏បានកំណត់គោលដៅ៣នៃការធ្វើគោលនយោបាយការបរទេស (រួមមាន៖ គោលដៅជួរខ្លី មធ្យម និងវែង) ហើយក៏បានកំណត់កត្តា២សម្រាប់ការធ្វើគោលនយោបាយការបរទេស ដោយក្នុងនោះរួមមានកត្តាខាងក្រៅនិងកត្តាខាងក្នុង។

ចំពោះកត្តាខាងក្រៅមានចំនួន៥ដូចជា៖ រចនាសម្ព័ន្ធអំណាចពិភពលោក អង្គការអន្តរជាតិ ប្រតិកម្មរបស់រដ្ឋដទៃ មតិសាធារណៈពិភពលោកនិងសម្ព័ន្ធភាព។ រីឯកត្តាខាងក្នុងវិញមានចំនួន១០ ដូចជា៖ ឥទ្ធិពលផ្នែកប្រវត្តិសាស្ត្រ ទំហំទឹកដីនិងភូមិសាស្ត្រ ធនធានធម្មជាតិ ការអភិវឌ្ឍសេដ្ឋកិច្ច ការអភិវឌ្ឍឧស្សាហកម្ម អំណាចយោធា អភិបាលកិច្ចល្អនិងភាពជាអ្នកដឹកនាំ ចំនួនប្រជាជន គុណភាពនៃកិច្ចការផ្នែកទូតនិងអង្គការនយោបាយ។ ម៉ូដែលសំខាន់ៗចំនួន២ សម្រាប់វិភាគគោលនយោបាយការបរទេសប្រទេសទាំងពីរ ត្រូវបានលើកយកមកសិក្សា រួមមាន៖ ម៉ូដែលតួអង្គដែលប្រកបដោយហេតុផលនិងវិចារណញ្ញាណនិងម៉ូដែលនយោបាយការិយាល័យធិបតេយ្យ។

នៅក្នុងជំពូកនេះដែរក៏បានលើកឡើងពីទ្រឹស្តីសេរីនិយមជាទ្រឹស្តីសម្រាប់វិភាគការអនុវត្តគោលនយោបាយការបរទេសប្រទេសទាំងពីរ ហើយក៏មានការសិក្សាពីលក្ខខណ្ឌនៃការដំឡើងទំនាក់ទំនងរដ្ឋទៅជាភាពជាដៃគូយុទ្ធសាស្ត្រ និងភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ។ បន្ថែមពីលើនេះ ក៏មានការសិក្សាពីតថភាពពិតនៃពិភពលោក និងការនិទស្សន៍កម្រិតទំនាក់ទំនងអន្តររដ្ឋរវាងកម្ពុជានិងជប៉ុននាថ្ងៃ

អនាគតផងដែរ។ សម្រាប់ជំពូកទី២ គឺមានចំណងជើងថា «ទំនាក់ទំនងកម្ពុជា-ជប៉ុន»។ ក្នុងជំពូកនេះ គឺសិក្សាស្រាវជ្រាវទាក់ទងនឹងទិដ្ឋភាពទូទៅនៃប្រទេសកម្ពុជា-ជប៉ុន ប្រវត្តិនៃទំនាក់ទំនងរវាងកម្ពុជា-ជប៉ុន មុនឆ្នាំ២០០៨ គោលនយោបាយការបរទេសប្រទេសទាំងពីរជាសង្ខេប គោលនយោបាយការបរទេសប្រទេសទាំងពីរចំពោះគ្នាទៅវិញទៅមក ក៏ដូចជាគោលការណ៍ទូទៅនៃគោលនយោបាយការបរទេសប្រទេសទាំងពីរពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៨។

បន្ថែមពីលើនេះ ក្នុងការសិក្សានេះក៏លើកឡើងពីទិដ្ឋភាពរួមនៃទំនាក់ទំនងប្រទេសទាំងពីរពីឆ្នាំ ២០០៨ ដល់ឆ្នាំ២០១៨ ដោយក្នុងនោះរួមមាន៖ ការគាំទ្រគ្នាទៅវិញទៅមកលើឆាកអន្តរជាតិ ការផ្លាស់ប្តូរទស្សនកិច្ចរវាងប្រទេសទាំងពីរ និងកម្ពុជានៅចន្លោះជប៉ុននិងចិន។ រីឯ ជំពូកទី៣ គឺមានចំណងជើងថា «ទស្សនវិស័យនៃទំនាក់ទំនងកម្ពុជា-ជប៉ុន»។ ក្នុងជំពូកនេះ គឺផ្តោតការសិក្សាអំពីទិដ្ឋភាពនយោបាយ ទិដ្ឋភាពសេដ្ឋកិច្ច បញ្ហាប្រឈមនៃទំនាក់ទំនងកម្ពុជា-ជប៉ុន និងអនាគតនៃទំនាក់ទំនងប្រទេសទាំងពីរជារួម។